# កិច្ចសម្ភាសអ៊ុំស្រីឈ្មោះ ឡុង សាវី

ក៖ អ្នកសម្ភាសឈ្មោះហេង សុជីវី ខ៖ អ្នកត្រូវគេសម្ភាសឈ្មោះ ឡុង សាវី

ក៖ ចាសអ៊ុំជំរាបសួរអ៊ំ!

ខ៖ ចាសជំរាបសួរអូន!

ក៖ ចាសថ្ងៃនេះខ្ញុំមានឱកាសមកសម្ភាសអ៊ុំផ្ទាល់ខ្ញុំធ្វើការនៅគំរោងស្ម័គ្រចិត្តរបស់សាលា BYUរបស់សហរដ្ឋអាមេរិកណាអ៊ំ!

ខ៖ ចាស!

ក៖ ហើយគំរោងនិងគេចង់ជួយចងក្រងពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាដែលមានវ័យចាប់ពី៣៥ឆ្នាំឡើងទៅពីជីវិតបទពិសោធន៍របស់គាត់ដែលបានឆ្លងកាត់មកដើម្បីគេនិងបានចងជាឯកសារទុកឲ្យកូនចៅជំនាន់ក្រោយគេបានស្គាល់អ៊ំ!

ខ៖ ចាស!

ក៖ ចាស! ហើយអញ្ចឹងជាដំបូងនៃការសម្ភាសនាងខ្ញុំសុំសួរអ៊ុំសិនតើអ៊ុំអនុញ្ញាតិឲ្យខ្ញុំធ្វើការថតសំលេងរបស់អ៊ុំហើយនិងយករូបរបស់អ៊ំយកទៅផុសក្នុងវេបសាយបានដែរឬទេអ៊ំ?

ខ៖ ចាស!

ក៖ ចាស! អ៊ំការសម្ភាសនមុនដំបូងនៅថ្ងៃនេះគឺជាថ្ងៃទី៣១ខែ៧ឆ្នាំ២០១៨ការសម្ភាសមុនដំបូងខ្ញុំឈ្មោះហេង សុជីវី ជាអ្នកសម្ភាសហើយសុំសួរឈ្មោះអ៊ំតើអ៊ំមានឈ្មោះអីដែរអ៊ំ?

ខ៖ អ៊ំឈ្មោះ ឡុង សាវី!

ក៖ ចាសអ៊ំឈ្មោះនិងត្រូវជាមួយអត្តសញ្ញាណប័ណ្ណទេ?

ខ៖ ហ្នឹងហើយត្រូវគ្នាអូន!

កៈ មានឈ្មោះហៅក្រៅទេអ៊ំ?

ខៈ អត់ទេ!

កៈ អត់មានទេអ៊ំន៎?

ខៈចាស!

កៈ ហើយឈ្មោះនិងឪពុកម្ដាយរបស់អ៊ំជាអ្នកដាក់ឲ្យមែនទេ?

ខៈ ដាក់ឲ្យម៉ង!

កៈ គាត់មានប្រាប់ថាឈ្មោះហ្នឹងមានអត្ថន័យយ៉ាងណាទេបានជាគាត់ដាក់ឲ្យឈ្មោះហ្នឹង?

ខៈ គាត់ថាគាត់ចូលចិត្តតែឈ្មោះហ្នឹង ព្រោះអីឈ្មោះបងប្អូនគាត់ស្រដៀងៗនិងដែរហ្មាស!

កៈ ចាស!

ខៈ ក៏ដាក់ឈ្មោះហ្នឹងទៅ!

កៈ ចាសអ៊ុំ ហើយសព្វថ្ងៃអ៊ុំអាយុប៉ុន្មានហើយ?

ខៈ អ៊ំសព្វថ្ងៃអ៊ំ៦២ហើយក្មួយ!

កៈ អ៊ំកើតឆ្នាំណាដែរអ៊ំ?

ខៈ អ៊ំអត់ចាំទេអូនអើយយូរដែរអូនអើយតាំងពីសង្គមមកម្លេះ!

កៈ អញ្ចឹងមានអត្តសញ្ញាណប័ណ្ណទេអ៊ំ?

ខៈ អត្តសញ្ញាណប័ណ្ណមានតើតែនៅផ្ទះណោះអូន!

កៈ អត់យកមកទេ?

ខៈ អត់យកមកទេផ្ទះនៅស្ទឹងមានជ័យឯណោះ!

កៈ ចុះអ៊ំចាំថាអ៊ំកើតឆ្នាំសត្វណាកើតនៅឆ្នាំណាដែរ?

ខៈ ឆ្នាំអាឆ្នាំនឹងវាមិនចាំទៀតណាអូនអើយ!

កៈ ចាសស្រុកកំណើតអ៊ុំវិញមានស្រុកកំណើតនៅឯណា?

ខ៖ នៅកំពង់ស្ពឺអូន!

ក៖ នៅភូមិឃុំអីដែរ?

ខ៖ ភូមិ វល្លិ៍ស ខេត្តកំពង់ស្ពឺ ស្រុកភ្នំស្រួច!

ក៖ ចាស!

ខ៖ ចាស!

ក៖ ហើយសព្វថ្ងៃអ៊ំមានទីលំនៅនៅឯណាដែរ?

ខ៖ អ៊ំសព្វថ្ងៃគ្មានទេអូនតែលគោលពីមុនទៅនៅនឹងវត្តលោកឯកើតឯណោះ ហើយដល់ឥលូវទៅជួលផ្ទះនៅស្ទឹងមានជ័យ!

ក៖ ចាសផ្ទះនិងអ៊ំជួលតម្លៃប៉ុន្មានដែរ?

ខ៖ អ៊ំជួល ផ្ទះអ៊ំតម្លៃមួយខែ៧០(ដុល្លា)អូន!

ក៖ ចុះនៅភូមិឃុំសង្កាត់ណាដែរ?

ខ៖ ខណ្ឌនេះបឹងត្របែក!

ក៖ បឹងត្របែក!

ខ៖ ចាសខ្ញុំមកនៅហ្នឹងភ្នំពេញហ្នឹងយូរដែរហើយ!

ក៖ ចុះអ៊ំនៅជាមួយក្រុមគ្រួសារទាំងអស់គ្នាឬអ៊ំនៅតែម្នាក់ឯង?

ខ៖ នៅគ្រួសារអ៊ំនិងទាំងអស់!

ក៖ ចាស! ប៉ុន្មាននាក់ដែរអ៊ំ?

ខ៖ កូនខ្ញុំ៥នាក់!

ក៖ គាត់ឈ្មោះអីខ្លះដែរអ៊ំកូនរបស់អ៊ំ?

ខ៖ កូនបងគេឈ្មោះស្រីរ៉ាត់ ក្រោយមកទៀតឈ្មោះ រ៉ុង អឺ...រ៉ុង រ៉ា ហើយមួយទៀតឈ្មោះ រ៉ុង អឺ...រ៉ុង រដ្ឋា  រ៉ុងថន រ៉ុង លក្ខ័ រ៉ុង ភ័ក្រ្ត អស់ហើយអូន!

ក៖ ចាសអ៊ំ! កូនប៉ុន្មានអ៊ំៗកូន៥នាក់និងស្រីប៉ុន្មានប្រុសប៉ុន្មានដែរអ៊ំ?

ខ៖ ស្រីពីរប្រុសបួន(បី)!

ក៖ ចាស! គាត់ទាំងអស់បានចូលសាលារៀនទាំងអស់គ្នាតើអ៊ំ?

ខ៖
ហើយអូនហើយរៀនដែរតែរៀនវាអត់កប់ទេអូនព្រោះម៉ែក្រពេកកូនឈប់ទៅរកស៊ីចិញ្ចឹមគ្នាទៅវិញទៅមកទាំងអស់គ្នា!

ក៖ អឺ...

ខ៖ ចាសទូលនំលក់!

ក៖ ចុះស្វាមីអ៊ុំមានឈ្មោះអីដែរឬ?

ខ៖ ស្វាមីខ្ញុំឈ្មោះរ៉ុង ប៉ាគាត់ឈ្មោះផលហើយគាត់ឈ្មោះរ៉ុង គឺ រ៉ុង ផល!

ក៖ ចាស!

ខ៖ ចាស!

ក៖ អញ្ចឹងស្វាមីរបស់អ៊ំធ្វើមុខរបរអីគេដើម្បីចិញ្ចឹមជីវិត!

ខ៖ អឺ...ខ្ញុំអត់រកអីទេបំរើរលោកតាំងពីអើយមកហើយ តាំងពីដាច់អាពត មក!

ក៖ អឺ...

ខ៖ ហើយប្ដីខ្ញុំរត់ម៉ូតូឌុប គ្រាន់តែចាយខ្លួនឯងមិនគ្រប់ផង!

ក៖ ដល់ពេលល្ងាចទៅបានអ៊ំអញ្ជើញទៅវិញ?

ខ៖ ទៅផ្ទះចាស ក្រោយពីលោកឆាន់ពីថ្ងៃត្រង់អ៊ំទៅផ្ទះ អ៊ំអត់ធ្វើអីនៅផ្ទះ មានតែធ្វើនេះទៅបើធ្វើអិកើតចំណាស់នេះហើយ!

ក៖ ចាសអ៊ំអញ្ចឹងដូចជាសមាជិកគ្រួសារអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមួយពោះខ្ញុំឬមួយពោះកូនខ្ញុំ?បើមួយខ្ញុំមានតែមួយតែឯង!

ក៖ អឺ...

ខ៖ ខ្ញុំណាស់កើតមកកំសត់ណាស់មានតែមួយជាមួយម៉ែ!

កៈ កូនទោលអញ្ចឹង?!

ខៈ ចាសហើយម៉េខ្ញុំកើតមកមិនបានឃើញមុខម្ដាយយ៉ាងមិចទេ ស្លាប់បាត់ទៀតណាបងប្អូនអ្នកប្រាប់!

កៈ អឺ...

ខៈ បងប្អូនជីដូនមួយខាងឪពុកខ្ញុំហ្អាស ស្លាប់តាំងពីមិន៧ឆ្នាំផងខ្ទង់ប្រហែលអាយុ៦ឆ្នាំនិង ហើយបានមប៉ុន្មានឆ្នាំបានឪពុកស្លាប់ទៀត!

កៈ ចាស!

ខៈ ឪពុកស្លាប់ហើយនៅជំនាន់អាពត ចាសជំនាន់អាពតនិងគឺថា នៅតូចកុមារ ផង នារីផង ធ្វើការរែកដី កាប់អាចម៍គោ ធ្វើជីយកលាមកយើងមកធ្វើជី មិនដឹងបាយមិនដឹងទឹកទេ ធ្វើទៅទាល់តែខ្យល់ចាប់ដេកដួល នៅក្រោមដើមឈើនិង ហើយគេថាអូមិត្តនារីនេះឈឺហើយ ហើយយកថ្នាំឲ្យគ្នាលេបមិនដឹងថ្នាំស្អី ថ្នាំប៉ិននិងលេបមិនចូលទេនៅក្រោមដើមឈើនិងញ៉ាក់ មិនស្គាល់គ្រុនមិច កាលនិងទៅដកទាំងឈឺទាំងជាជំនាន់អាពតអូនហើយ!

កៈ អឺ...

ខៈ ចាស!

កៈ ចុះកាលជំនាន់អាពតគេជំលៀសអ៊ុំទៅណាដែរ?

ខៈ អំគេជំលៀសទៅភ្នំដងរែកឯណោះ ទៅភ្នំដងរែក!

កៈ ចាស!

ខៈ ហើយទៅដល់ភ្នំស្អីគេទេភ្នំនឹងខ្ពស់ណាស់ ភ្នំអីៗទេច្រើនណាស់!

កៈ អឺ...

ខៈ ប្រវត្តិសាស្ត្រអ៊ុំកំសត់ណាស់ គ្មានបងគ្មានប្អូន ចេះតាមគេ អាត្រាត់អាត្រែងទៅណា!

កៈ អឹម!

ខៈ រស់នៅជាមួយគេយូរៗទៅអាពតវាចាប់យើងផ្សំផ្គុំឲ្យម្នាក់ដែលយើងមិនដឹងខ្លួនណា!

កៈ ចាស!

ខ៖ប៉ុន្តែរយើងខ្លាចងាប់ចេះតែទៅតាមគេទៅ ប៉ុន្តែសមថ្ងៃគាត់នៅសមប្រកបជាមួយខ្ញុំទល់មកសព្វថ្ងៃនិង អ្នកខ្លះក្រោយជំនាន់អាពតបែកគ្នាអស់ រត់ទៅស្រុកគេវិញ យើងមកស្រុកយើងវិញណាតែខ្ញុំដូចដឹងថា ដឹងស្រាប់ហើយអាពត មិនឲ្យចោលទេ ឲ្យចាប់ដៃគ្នាដល់ចាស់ស្លាប់រៀងខ្លួន មែនដល់ចាសស្លាប់រៀងខ្លួនមែនកូនឯងមើល!

ក៖ (សើច)!

ខ៖ អត់ទៅណាទេទោះបីឈ្លោះ ប្រកែកគ្នាយ៉ាងណានៅតែប៉ុណ្ណឹង!

ក៖ អឺ...

ខ៖ ឆ្ងល់ខ្ញុំដល់ហើយ!

ក៖ ចាស! ហើយអ៊ុំកាលនិងមានកូនជំនាន់អាពតដែរអ៊ុំន៎?

ខ៖ អត់មានទេអូន!

ក៖ ទាល់តែដាច់មកហ៎?

ខ៖ នៅនិងគ្រាន់តែរៀបគ្នាហើយបានទេមួយអាទិត្យបែកគ្នាអឺ...បែកវិញ!

ក៖ ចាស !

ខ៖ ចាស!

ក៖ ចាស!

ខ៖ គេទៅបណ្ដោះយើងមក!

ក៖ ចាស! អ៊ំកាលនិងគេធ្លាប់ធ្វើបានអ៊ំខ្លាំងទេកាលជំនាន់អាពតហ្នឹង?

ខ៖ អូនហើយវេទនាណាស់ មិនដែលស្គាល់ស៊ីម៉េចឆ្អែតដេកពួនម៉េច ច្រូតទាំងយប់ទាំងយប់កាប់ដីទាំងយប់ស្ទូងទាំងយប់អត់មានដឹងភ្លឺ ឃើញពន្លឺព្រះអាទិត្យមិចទេ!

ក៖ អឺ...

ខ៖ អូនហើយវេទនាណាស់ខ្ញុំទៅស្ទូងអញ្ចឹងលេងទឹកជន់មក ទឹកហៀរមកត្រឹមនេះៗមិនមកពីណាហើយឯងមិនទៅខាងណាទេលោកអើយ ហើយផ្លេកបន្ទោលមកក្តឹងៗមករត់ទៅតាមភ្លឺស្រែដួលខ្ពោកទៅមានអ្នកដែលស្គាលចាប់ទាញខ្ញុំលើកមក ចុះខ្ញុំតូចជាងគេហ៎គេធំៗគេចាប់ទាញកអាវមកដូចថាៗទឹកជំនន់ ទឹកអីម៉េចដូចគេផ្សាយក្នុងទូរទស្សន៍យើងរាល់ថ្ងៃអញ្ចឹងណា!

ក៖ ចាស!

ខ៖ មកទាំងក្មេនៗហើយអាងតែគេពួកគេធំៗហើយធ្លាប់នៅនិងពួកគេៗហៅខ្មែរក្រហមហ៎!

ក៖ ចាសអ៊ំ!

ខ៖ គេមិនទៅជួយអីយើងគេទៅរួចតែខ្លួនគេទៅ កំពុងតែស្ទូងដកទាំងអស់គ្នាអូនវេទនាណាស់ចេះមានអីដែរគេទៅជួយរំដោះបានមកដល់ភ្នំពេញហ្នឹងទៅ!

ក៖ ចាស!

ខ៖ អាដីស្រែក៏អត់ អាដីចំការក៏អត់ អាផ្ទះនៅសព្វថ្ងៃនៅជាមួយគេ!

ក៖ ចាស!

ខ៖ ឥលូវគេងាប់បាត់ទៅយើង!

ក៖ ហើយ...

ខ៖ បែកគ្នាអស់ហើយមិនដឹងទៅណាទៅណីទេ!

ក៖ ចាស! ហើយអ៊ំកាលនិងគេឲ្យអ៊ំធ្វើការប៉ុន្មានម៉ោងដែរ?

ខ៖ ហើយអូនហើយធ្វើនោះធ្វើគ្មានពេលទំនេរទេគេមិនអោយយើងទំនេរដឹងម៉ោងទំនេរ!

ក៖ ចុះអ៊ំដេកបានប៉ុន្មានម៉ោងដែរ?

ខ៖ ហើយកម្រណាស់អូនហើយអូន ទាល់តែឆ្លៀតដេកយប់ឡើងអញ្ចឹងទៅយប់ឡើងដេកបានប្រហែលជាមួយម៉ោងកន្លះម៉ោងគេហៅទៅទៀតហើយទៅធ្វើការទៀតហើយវ៉ៃអាគាំង(វ៉ៃជួង) ផ្អើលគ្មានបានដេកទេដេកបានតែបន្តិចៗទេគេហៅទៅយើងត្រូវតែទៅ!

ក៖ អឺម...

ខ៖ ស្លៀកខោពាក់អាវទាំងសើមពេញទាំងខ្លួនទាំងអស់ហើយយើងមានខោឯណាស្លៀកពាក់មានតែមួយកំប្លេរទៅងូតទឹកទៅមកវិញស្ងួតផ្អាប់ទៅ ដេកទាំងអញ្ចឹងទៅគេហៅរ៉ែអាគាំង(ជួង)ទៅទៀត ជួនកាលទៅក៏បានពីម៉ោងដែរណា អញ្ចឹងជំនាន់អាពតអញ្ចឹងឯង!

ក៖ ចាស!

ខ៖ គេមិនឲ្យហូបបាយទេហូបស្លឹកឈើ ស្លឹកអី ស្លឹកល្ហុង!

ក៖ អឹស!

ខ៖ កញ្ច្រាំ ស្ងោរ ហូប សូម្បីតែអំបិលតែមួយដុំសុំគេហូបក៏គេមិនឲ្យហូបផង!

ក៖ អឺ...

ខ៖ គេបោះបាយក្តាំងចោលទៅរើសបាយក្តាំងគេមកចាំងៗទៅខ្មៅអញ្ចឹងចាំងៗយកមកអង្កៀមៗទៅចែកគ្នាម្នាក់បន្តិចៗទៅទាំងអស់គ្នានិងហូបទៅណា!

ក៖ អឺ...ចុះអ៊ំធ្លាប់ឈឺអត់ជំនាន់អាពតហ្នឹង?

ខ៖ ជំនាន់អាពតហ្នឹង?

ក៖ ចាស!

ខ៖ ដឹងឈឺអី មានតែផ្តាសាយ គ្រុនចាញ់ គ្រុនញាក់តែប៉ុណ្ណឹង!

ក៖ អឺម...ហើយអ៊ំកាលនិងអ៊ំធ្លាប់ឃើញអាពតយកមនុស្សទៅសម្លាប់ផ្ទាល់ភ្នែកទេ?

ខ៖ កំពុងតែដេកៗគេហៅផ្ទះនោះអញ្ចឹងទៅ ញ៉ាក់អស់ហើយ ស្អែកឡើងអញហើយសង្ស័យណាស់គេចាំអង្កេតមើលយើងមានឈ្លបគេនិង អាងម៉េចៗអាងយើងទៅធ្វើការជាមួយគ្នាចេះអត់អីដែរអញ្ចឹងទៅ ធម្មតាៗទៅដូចបងប្អូនយូរៗទៅមានអី!

ក៖ ចាសអ៊ំ! ហើយអញ្ចឹងដូចជាការជំនាន់អាពតនិងបងប្អូនអ៊ំទាំងអស់គេជំលៀសទៅជាមួយគ្នាអ៊ុំន់?

ខ៖ អត់ទេអូនទៅឆ្ងាយពីយើង យើនៅជាមួយគេអ្នកដទៃហ្នឹង អត់មានស្គាល់គេផងចេះតែទៅហ្នឹងគេនឹងឯងហើយ អាសាច់ឈាមយើងក៏បាត់ទៅមិនដឹងនៅឯណាព្រោះខ្លាចរៀងៗខ្លួនហ៎!

ក៖ ចាស!

ខ៖ ប្រើៗទៅមិនដឹងគេទៅណាទៅតាមគេរហូត ក៏នៅជាមួយគេយូរៗទៅស្គាល់គេស្គាល់ឯង!

ក៖ ដល់ពេលបានបែកទៅបានជុំគ្នាវិញ?

ខ៖ បានជុំគ្នាទៅ!

ក៖ ចុះបងប្អូនអ៊ំមានស្លាប់ជំនាន់អាពតទេ?

ខ៖ ជំនាន់អាពតនិយាយទៅទាំងគ្រួសារៗ បងជីដូនមួយខ្ញុំមីងខ្ញុំអីទៅអស់ខ្លះទៅទាំង៥នាក់ទៅខ្លះទៅ២នាក់ទៅ មកដល់ភូមិស្រុកទៅអស់រលីងសល់ចាស់គ្នាប៉ុន្មាននាក់ហ្នឹង!

ក៖ តែបងប្អូនអ៊ំអត់មានស្លាប់ជំនាន់អាពតទេអ៊ុំ?

ខ៖ អត់ទេខ្ញុំអត់ទេ!

ក៖ អឺ...អត់មានទេចាស!

ខ៖ ចាសតែឯងសុទ្ធសាធម៉ងម្ដាយក៏ឪពុកក៏អត់ដែរ រស់ដោយសារគេទេនៅជាមួយគេ!

ក៖ ដល់ពេលដាច់មកអ៊ំចង់ចាំអីគេខ្លះដែរកាលនឹង?

ខ៖ ចងចាំមកពីអាពតវិញហ្អែស?

ក៖ ចាស! ដូចជាដាច់ពីជំនាន់អាពតមកវាលំបាកអីគេខ្លះរហូតមក!

ខ៖ អឺ...អូនហើយលំបាកហួសលំបាកហើយមកតាមផ្លូវគ្មានអង្ករគ្មានទឹកត្រីអីទេចេះតែរស់និងគេរស់និងឯងមកតាមគេអញ្ចឹងរហូតមកខ្លះគេមានទៅគេឲ្យយើងហូបអញ្ចឹងទៅណាដល់មកដល់ស្រុកដល់ភូមិនឹងបងប្អូនគេៗមានដីមានធ្លីនៅអស់រលីងខ្ញុំអត់មាននិងគេរត់ចេញពីទៅ មកនៅភ្នំពេញ ដល់នៅភ្នំពេញយូរៗប្ដីខ្ញុំឈឺទៅនៅន៎គេហៅថាស្រុកថៃហ៎ !

កៈ ចាស!

ខៈ ទៅនៅថៃបានប៉ុន្មានឆ្នាំថៃគេឲ្យមកវិញមក អស់ដីអស់ស្រែរលីង ផ្ទះនៅរកផ្ទះនៅមិនបាន ជួលផ្ទះគេនៅសព្វថ្ងៃហ្នឹងៗ ទៅស្រុកទៅស្រែឃើញដីម៉ែបងប្អូនអង្គុយយំស្តាយ ស្តាយបានគេធ្វើមិនក្រមកពេកធ្វើម៉េច អត់ទៅមួយជាតិនេះរកដីស្រែនិងគេមិនឃើញ សូម្បីតែដីប៉ុនកដៃនៅស្រុកនោះគ្មានផង!

កៈ ចាស!

ខៈ រកតេលុយទិញឈើមកធ្វើផ្ទះនៅក៏គ្មានផង!

កៈ ចាសអ៊ំ! អញ្ចឹងកូនបងប្អូនអ៊ុំក្រុមគ្រួសារអីគាត់ដូចជាទំនាក់ទំនងរាល់ថ្ងៃធម្មតាឬក៏យ៉ាងណាដែរ?

ខៈ អ្នកនៅស្រុកហ្នឹងហ៎?

កៈ បងប្អូនអ៊ំបង្កើតណា និងសាច់ញាតិដែលត្រូវជាបងប្អូនអ៊ំណាអ៊ំមិចដែរឥលូវ?

ខៈ បងប្អូនជីដូនមួយគេមានមានទំនាក់ទាក់ទងអីស្គាល់គ្នាដែរ ប៉ុន្តែរគេរស់ដោយគេ យើងរស់ដោយយើង!

កៈ អឺ...ចុះបងប្អូនបង្កើតវិញ?

ខៈ បង្កើតថាអត់មានទេខ្ញុំតែឯង!

កៈ ចាស!

ខៈ កើតមកអត់មានបងមានប្អូនអីទេ!

កៈ ចាស!

ខៈ ម៉ែខ្ញុំកូនតែមួយ!

កៈចាស!

ខៈ ខ្ញុំមួយតែឯងនិងម៉ែខ្ញុំ ឪស្លាប់ទៅតែឯងឆ្អឹងដូចដើមត្នោតទៅ!

កៈ អឺ...មានជីដូនមួយអី សាច់ញាតិអីមានប៉ុន្តែ!

ខៈ សាច់ញាត់អីមាន!

កៈ អញ្ចឹងឪពុកម្ដាយរបស់អ៊ំគាត់ឈ្មោះអីដែរ?

ខៈឪពុកខ្ញុំឈ្មោះអឺ...ឡេ្ងា អឺ...ឡុង ឡេ្ងា និងឪពុកខ្ញុំណា!

កៈ ចាស!

ខៈ ហើយម៉ែខ្ញុំៗឈ្មោះ វន!

កៈ ចាស!

ខៈ ហើយម៉ែរបស់ខ្ញុំម៉ែខ្ញុំនិងឈ្មោះសួន!

កៈ គាត់ទាំងអស់គ្នានិងមានអាយុប៉ុន្មានហើយអ៊ំបានគាត់ស្លាប់ទៅ?

ខៈ អូ...បើស្លប់ប្រហែលជា បើអ៊ំខ្ញុំមួយនោះប្រហែលជាជិត៩០ឆ្នាំ៩១ អ៊ុំប្រុសនិងចូលប្អូនយាយខ្ញុំ១០ឆ្នាំ បើអ៊ំខ្ញុំមួយទៀតនៅខាងឪពុកខ្ញុំនឹងអាយុច្រើនហើយតែមិនចាំ!

កៈ ចាស! ហើយឪពុកម្ដាយអ៊ំគាត់ស្លាប់ឬនៅ?

ខៈ ស្លាប់តាំងពីសង្គមហ៎!

កៈ តាំងពីសម័យរាស្ត្រ សម្ដេច?

ខៈ និងហើយ!

កៈ មូលហេតុអីកាលនឹងទាន់ទេ?

ខៈ ឪពុកខ្ញុំគាត់ឈឺគ្រុនញ៉ាក់ ម្ដាយខ្ញុំទៅស្លាប់នឹងទន្លេរបួនមុខហ្នឹង លង់កាណូត លង់កាប៉ាល់ហ៎ កាលគេទៅត្រើយម្ខាងទៅបុណ្យហ៎ ទៅបុណ្យកឋិនទៅ កប៉ាល់លិចនៅមុខវាំងៗភ្នំពេញយើងហ្នឹង!

កៈ ហ្នឹងហើយ!

ខៈ ទន្លេរបួនមុខនេះស្លាប់នៅនិងទៅ ចំណែកឪពុកខ្ញុំទៅស្រុកគេរកស៊ីស្រុកគេស្លាប់ស្រុកគេទៅស៊ីឈ្នួលស្រុកគេស្លាប់នៅក្នុងស្រុកគេទៅ!

កៈ ចុះកាលហ្នឹងមានកប៉ាល់អីលិចដែរ?

ខ៖ យី! យូរហើយអូនតាំងពីសង្គម តាំងពីខ្ញុំនៅអាយុ៦ឆ្នាំន់បងប្អូនអ្នកប្រាប់អ្នកភូមិគេប្រាប់ទាំងអស់!

ក៖ ចាស! ហើយគេថាម៉េចទៅអ៊ំ?

ខ៖ កប៉ាល់និងឆ្លងទៅវត្ត ឥន្ទសី!

ក៖ សំរាប់ដឹងមនុស្សកប៉ាល់និង?

ខ៖ ហែរទៅមនុស្សច្រើនអូន គ្រាន់តែកប៉ាល់៥ទៅ៦ផុតត្រឹមកប៉ាល់ម៉ែខ្ញុំ!

ក៖ អឺ...

ខ៖ វាគឿងនៅនិងក្រោមដឹងស្អីគឿងនៅខាងក្រោម លិចផ្លឹបជួយមិនទាន់ស្លាប់អស់ ហើយម៉ែខ្ញុំគាតើស្លាប់និងកប៉ាល់និងទៅ បានជាខ្ញុំសព្វថ្ងៃខ្លាចទឹកណាស់ !

ក៖ អឺ...ហើយអ៊ំហើយអ៊ុំមានដឹងថាគាត់កើតនៅក្នុងថ្ងៃខែឆ្នាំណាទេអ៊ំ? ហើយមានស្រុកកំណើតនៅណាអ៊ំមានដឹងពីពត៍មានឪពុកម្ដាយអ៊ំទេ?

ខ៖ ឪពុកម្ដាយខ្ញុំនៅភូមិជិតៗគ្នាហ្នឹង ចាំខ្ញុំប្រាប់ម៉ែខ្ញុំនៅភូមិ វល្លិ៍ស ឪពុកខ្ញុំនៅព្រៃកោះជាប់គ្នាភូមិនិងណាអូនណា ប្រហែលពីកន្លះគីឡូ)មួយគីឡូពីគ្នានិង នៅភូមិជាប់ៗគ្នានឹងស្មឹងហ្នឹង!

ក៖ អឺ...ចាស! ហើយអ៊ំលហ្នឹងអ៊ំមានដឹងថាគាត់ធ្វើអីដើម្បីចិញ្ចឹមជីវិតទេអ៊ំ?

ខ៖ ឪពុកខ្ញុំគាត់រតើរ៉ឺម៉កផងកង់យើងនិងអាកង់ធាក់និងជើងនិងដើម្បីចិញ្ចឹមកូន ចិញ្ចឹមពួកខ្ញុំនិង
ដល់ចិញ្ចឹមយូរៗទៅគាត់ចាស់ទៅគេហៅបបួលគាត់ទៅធ្វើបុណ្យនៅភ្នំស្រង់ដល់ពេលទៅឪពុកខ្ញុំគាត់ហូបអីគេទេលាប់ក្ដៅខ្លួនប្រហែលជាកន្លះខែបានស្លាប់មានអ្នកប្រាប់ខ្ញុំណា!

ក៖ ចាស!

ខ៖
គេថាគាត់ផ្ដាំគេអោយមើលថៃកូនខ្ញុំផងប៉ុន្តែគេភូមិស្រុកគេឯណោះគេមិនស្គាល់ស្រុកយើងផងមិនដឹងឯណាឯណី!

ក៖ ចាសអ៊ំ!

ខ៖ ស្លាប់ទៅ!

ក៖ ចុះម្ដាយអ៊ំវិញ?

ខ៖ ម៉ែខ្ញុំស្លាប់លង់កប៉ាល់នៅទន្លេ!

ក៖ និងហើយអ៊ំ ប៉ុន្តែរគាត់មានមុខរបរអីដែរ?

ខ៖ គាត់មានមុខរបរអីគាត់ពីដើមដូចថាលឺសួរបងប្អូននិយាយថាធ្វើស្រែ ធ្វើស្រូវទេអត់មានធ្វើអីផ្សេងទេគាត់ហ្នឹង!

ក៖ គាត់ជាមនុស្សបែបណាដែរ?ទាំងឪពុកទាំងម្ដាយអ៊ំ?

ខ៖ ម៉ែខ្ញុំកំសត់កម្រដែរនឹង កាលពីសង្គមនោះមនុស្សស្រីយើងមានទៅរកស៊ីអីប្ដីទៅរកនឹងហើយគាត់នៅផ្ទះមើលកូនទៅ!

ក៖ ចាសអ៊ំ! អញ្ចឹងអ៊ំគាត់មានធ្លាប់ប្រាប់អ៊ំថាជីវិតគាត់កាលនៅក្មេងៗម៉េចដែរអ៊ំ?

ខ៖ អឺ...ជីវិតម៉ែខ្ញុំកាលនៅក្មេងដូចជាគ្រាន់បើជាងខ្ញុំដែរនិង មានតែលំបាកលំបិនដូចពួកខ្ញុំទៅព្រៃទៅភ្នំក្រំថ្ម ឯណាគាត់នៅតែផ្ទះនឹងម៉ែឪគាត់ចិញ្ចឹមគាត់បានរៀនបានអីដែរនិងអត់តែខ្ញុំ រៀនមិនស្គាល់អក្សររបៀបម៉េចទេ អត់ស្គាល់អក្សររបៀបម៉េច ឥលូវក៏ល្ងង់ហើយភ្នែកក៏មើលមិនឃើញទៀត!

ក៖ ហើយអ៊ំកាលហ្នឹងរៀនបានថ្នាក់ទីប៉ុន្មានដែរអញ្ចឹង?

ខ៖ អ៊ំអត់បានរៀនទេកូនអើយ ចូលសាលានិងគេដែរចូលអត់កើតវាឈឺពេក!

ក៖ អូ!

ខ៖ ឈឺណាស់កាលនឹងឈឺ!

ក៖ បានថ្នាក់ទីប៉ុន្មានកាលហ្នឹងអ៊ំ?

ខ៖ ហើយអូនហើយទៅរៀនបានទេមួយឆ្នាំគេថាមិនឲ្យរៀនខ្លាចងាប់និងសាលាគេទៅ ទៅផ្ទះទៅយកកូនសិស្សនឹងទៅផ្ទះឲ្យម៉ែព្យាបាលមើលៗទៅ!

ក៖ នៅសាលាណាអ៊ំកាលនឹង?

ខ៖ នៅភូមិខ្ញុំនៅវល្លិសហ្នឹង! សាលារៀនវល្លិ៍និងមានដល់សព្វថ្ងៃហ្នឹង!

ក៖ ចាស!

ខ៖ ចាស!

ក៖ អ៊ំអញ្ចឹងជីដូនជីតាអ៊ំវិញគាត់មានឈ្មោះអីដែរ? ទាំងខាងឪពុកទាំងខាងម្ដាយអ៊ំ?

ខ៖ ចាំមើលខាងពុកខ្ញុំឈ្មោះតា ហើយមិនចង់ទាំងស្គាល់ឈ្មោះរបស់តាខ្លួនឯងទៀតខ្ញុំគាត់ឈ្មោះតាខ្ញុំឈ្មោះតាឡុង តាខ្ញុំខាងឪពុកឈ្មោះតាឡុងហើយឈ្មោះយាយខឹម ដល់ខាងម្ដាយឈ្មោះយាយ សួន តាយ៉ាង និងខាងម្ដាយខ្ញុំ!

ក៖ ចាសអ៊ំ!

ខ៖ ចាស!

ក៖ ហើយគាត់កើតនៅឯណាដែរអ៊ំ?ហើយអ៊ំដឹងរឿងអីខ្លះអំពីជីដូនជីតារបស់អ៊ំ?

ខ៖ ដូចជាមិនដឹងទេអូនអើយកើនមិនទាន់ទេ!

ក៖ អឺម...អញ្ចឹងសំរាប់ក្រុមគ្រួសារវិញអ៊ំរស់នៅស្រុកកំណើតខេត្តនិងយូរបានប៉ុណ្ណាដែរ?

ខ៖ តិចដែរនិងអត់ទាន់ដឹងក្ដីមែនទែនផងបែកពីនិងមក!

ក៖ ចាស!

ខ៖ ចាស!

ក៖ ចុះអ៊ំមានបងប្អូននៅស្រុកក្រៅទេអ៊ំ?

ខ៖ នៅស្រុកក្រៅអត់មានផងអូន អត់មានទេ!

ក៖ ចាស! ហើយអ៊ំអញ្ចឹងជីវិតរបស់អ៊ំតាំងពីក្មេងមកដល់ឥលូវមានការផ្លាស់ប្ដូរអីគេខ្លះដែរ?

ខ ៖ ហើយអ៊ំកាលពីក្មេង ពិបាកណាស់អូនអើយមានងាដើររើសខ្យង់ រើសក្ដាមទៅលក់ទៅបានលុយទៅទិញអីហូបខ្លួនឯងទៅ មានបងប្អូនពិតមែនតែគេរស់តែខ្លួនគេយើងរស់តែខ្លួនយើងទៅ!

ក៖ ចាសអ៊ំ!

ខ៖ លំបាកណាស់អូនអើយ ដើរបេះស្លឹកអំពិលទៅលក់និងគេនិងឯងទៅបានលុយទិញសំលៀកបំពាក់ទៅណា អត់មានម៉ែឪណាចិញ្ចឹមយើងបើម៉ែឪស្លាប់អស់ហើយ!

ក៖ ចាស!

ខ៖ គេរកស៊ីចិញ្ចឹមជីវិតគេដែរយើងមានតែបងប្អូន!

ក៖ ចាស! អញ្ចឹងការងារដែលអ៊ុំបានធ្វើមានអីគេខ្លះដែរដើម្បីរកកម្រៃចិញ្ចឹមជីវិត?

ខ៖ ខ្ញុំៗធ្វើនំលក់!

ក៖ តែមួយនិងទេហ៎អ៊ំ?

ខ៖ ធ្វើនំលក់ទូលដើរលក់ទៅ ថ្ងៃឡើងខ្ញុំយកជញ្ជីងដើរថ្លឹងតាមផ្សារតាមសាលារៀនអញ្ចឹងទៅ ជញ្ជីងគេថ្លឹងមនុស្សនិងណា!

ក៖ ចាសៗអ៊ំ!

ខ៖ បានមួយថ្ងៃបីបួនប្រាំពាន់គ្រាន់និងចែកកូនចាយអញ្ចឹងទៅ ហើយខ្ញុំវាធ្វើអីកើតបើនៅក្មេងៗ កូនរៀនមិនកើតឃើញម៉ែពិបាកពេកឈប់រៀនទៅ!

ក៖ អឺ...!

ខ៖ វាថាម៉ែអើយទិញជញ្ជីងដើរថ្លឹងពីនាក់បងប្អូនអញ្ចឹងទៅ!

ក៖ ចាស!

ខ៖ ឥលូវនឹងធំៗរៀងៗខ្លួនដើរធ្វើសំណង់អស់ហើយ ចាសធ្វើសំណង់នឹងគ្រាន់បានលុយទុកជួលថ្លៃផ្ទះថ្លៃទឹកភ្លើងក្នុងមួយខែមួយរយជាង!

ក៖ អូ...

ខ៖ គ្រាន់តែទឹកអូនឯងមើល ទឹកបីម៉ឺនប្រាំ ភ្លើងនឹងប្រាំមួយម៉ឺនប្រាំ!

ក៖ ចាស!

ខ៖ អឹម! នៅគេយកថ្លៃសន្តិសុខយកថ្លៃផ្ទះថ្លៃនឹងអីក្នុងមួយខែៗអូនអើយចង់ចូលមួយម្ភៃម៉ឺនបាត់ទៅហើយ!

ក៖ ចាសអ៊ំ!

ខ៖ ហើយផ្ទះនឹង៨០ដុល្លារទៀត រកឲ្យតែគេមួយថ្ងៃៗ រកលុយទិញអង្ករហូបមិនឃើញទេអូនជូនកាលលោកចង់ឲ្យប្រាក់ខែយើងចង់បានបុណ្យ ជូនកាលកូនទៅធ្វើសំណង់ទៅបានលុយបង់ថ្លៃផ្ទះទឹកភ្លើងគេអីអញ្ចឹងទៅ!

ក៖ ចាស!

ខ៖ ចេះតែរស់គ្រេដរទៅអូនអើយ យើងវាក្រអញ្ចឹងហើយ!

ក៖ អញ្ចឹងអ៊ំដូចជាម្ហូបវិញតើអ៊ុំចូលចិត្តម្ហូបអីដែរតាំងពីក្មេងមក?

ខ៖ មានអីចូលចិត្តអីទេ សម្លរម្ជូរៗ យើងស្រែធម្មតានិងចុះរកលុយមកពីណាបានទិញម្ហូបល្អៗនិងគេ ដល់ពេលខ្ញុំចាស់ទៅបានមកនៅវត្តទៅបានម្ហូបហូបឆ្ងាញ់អញ្ចឹងទៅ!

ក៖ អឺម!

ខ៖ ដល់ទៅផ្ទះខ្លួនឯងអញ្ចឹងទៅថ្ងៃណាអត់មកវត្តអញ្ចឹងទៅ មានត្រីខឆាជាមួយស្ពៃឬមួយស្ងោរអញ្ចឹងទៅ!

ក៖ ចាស!

ខ៖ ប្រហុកអញ្ចឹងទៅ!

ក៖ អញ្ចឹងអ៊ំនៅវត្តនិងធ្វើអីដែរអ៊ំ?

ខ៖ អ៊ំជួយដាំបាយលោកបំរើសព្វគ្រប់ទៅលាងចានលាងឆ្នាំងជួយស្លរជួយដាំអញ្ចឹងទៅ!

ក៖ ប៉ុន្មានឆ្នាំហើយអ៊ំ?

ខ៖ អ៊ំនៅប្រហែលជា២៥ឆ្នាំហើយអ៊ំនៅនឹងវត្ត!

ក៖ អឺម!

ខ៖ ២៨ឆ្នាំហើយ!

ក៖ ចាស! ហើយកាលនៅក្មេងនិងដូចជាអ៊ំចូលចិត្តលេងល្បែងអ្វីខ្លះដែរកាលពីកុមារភាពនិងអ៊ំ?

ខ៖ អ៊ំចូលចិត្តលេងច្រៀងលេងរាំ លេងល្ខោន យីកេអញ្ចឹងចូលចិត្តណាស់ បើរៀនមិនចេះក្មេងកាលនឹង!

ក៖ អ៊ំមានទេពកោសល្យខាងហ្នឹង?

ខ៖ ចាសខាងល្ខោន យីកេ ហើយសព្វថ្ងៃនិងចាសចំណាស់និងហើយនៅសប្បាយអារឿងអញ្ចឹងៗទៀតណាខ្ញុំ!

ក៖ ចុះអ៊ុំមានស្រមៃទេកាលអ៊ំ នៅតូច មានស្រមៃថាធំឡើងអ៊ំចង់ធ្វើការងារអ្វីមួយដែរឬទេ?

ខ៖ អត់មានចង់អីទេចង់តែរៀនល្ខោនអាគ្រូល្ខោន យីកេនិង តែចង់តែអត់កំណើត!

ក៖ ចាស! ដល់ពេលធំឡើងអត់បានធ្វើ!

ខ៖ អត់ចង់ចុះបើយើង ធំជំនាន់អាពតបានអីធ្វើកើត!

ក៖ និងហើយ!

ខ៖ ចាស!

ក៖ ក្រោយមកក៏អ៊ំរកស៊ីចិញ្ចឹមជីវិតផ្សេងទៅ!

ខ៖ ហ្នឹងហើយ!

ក៖ ហើយចំរៀងវិញអ៊ំចូលចិត្តស្តាប់ទេអ៊ំ?

ខ៖ អូ...ចូលចិត្តណាស់អូនហើយសព្វថ្ងៃ ចំរៀងស្តាប់ ក្នុងទូរទស្សន៍មើលរាល់ថ្ងៃកំពុងមើលចំរៀងកូនបិទអីនិង អាឡាបល់យកំពុងមើលចំរៀងល្អមើលផង!

ក៖ បទអីដែរអ៊ំ ដែលអ៊ំចូលចិត្តស្តាប់?

ខ៖ បទសង្គមពីដើមហ្នឹង បទក្មេងសម័យឥលូវអត់ចូលចិត្តទេចូលចិត្តបទពីសង្គមពីដើមអញ្ចឹងណាស់ ចំរៀងពីដើមខ្ញុំចូលចិត្តស្តាប់បទកែវ សារាត់ នឹងចំណងចំណូលចិត្តយើងណា!

ក៖ ចាសៗ! អ៊ំមាននៅចាំបទណាមួយដែរទេដែលអ៊ំចូលចិត្ត?

ខ៖ ចូលចិត្ត ច្រៀងពីដើមសង្គមគាត់ច្រៀងថា គាត់ថាឱបាត់ដំបង ពូខ្ញុំគាត់ចូលចិត្តស្ដាប់ណាស់ ពីរនាក់ពូក្មួយនៅវាលស្រែហាំ!

ក៖ ចាស! ឱបាត់ដំបងបណ្ដូលចិត្តអើយនឹងហាំ?

ខ៖ ហ្នឹងហើយ! ចាស់ពីដើមៗនឹងជូនកាលនៅក្នុងចង្ក្រានវត្តតែម្នាក់ឯងច្រៀងក្នុងចង្ក្រាននៅវត្តក៏មានដែរ(សើច)!

ក៖ ចាស (សើច)! បង្កើតបរិយាកាស!

ខ៖ ហ្នឹងហើយ ក្នុងចង្ក្រានក៏ច្រៀងដែរ!

ក៖ អ៊ំហើយអញ្ចឹងនរណាគេនៅក្នុងគ្រួសារអ៊ំគាត់ចេះលេងឧបករណ៍ភ្លេង?

ខ៖ វាចង់នឹងចង់ដែរតែរៀនមិនចេះ ធ្វើការធ្វើងារទៅ!

ក៖ មាននរណាគេដែលចេះអត់អ៊ំ?

ខ៖ អត់មាននរណាចេះទេ បានប្រហែលកូនពៅខ្ញុំចូលចិត្តណាស់ច្រៀងចំរៀង!

ក៖ អ៎!

ខ៖ តែវាទិញហ្គីតាគេមកគេសុំកេះឲ្យគេកេះទៅនៅមួយទៀត ឲ្យគេសុំកេះបានត្រឹមតែទិញឥលូវ គេមិនទាន់ឲ្យលុយទេទិញមកច្រៀងខ្លួនឯងគេយកបាត់ទៅលុយឲ្យគេទៅឥលូវចង់មានទិញៗទៅមិនទាន់ឲ្យលុយផងទល់សព្វថ្ងៃនិង ហ្គីតាទិញមកពីរដេញពេញផ្ទះឯងថាហើយថ្លង់ណាស់ ហើយអានិងមួយទៀតចូលចិត្តកីឡាបាល់ៗទាត់ ឲ្យតែមកពីធ្វើការភ្លៀងយ៉ាងម៉េចក៏ទៅដែរកន្លះម៉ោងមកវិញហើយ!

ក៖ ចាស!

ខ៖ ឃើញអានិងមួយខុសគេ!

ក៖ គាត់មានទេពកោសល្យខាងហ្នឹង!

ខ៖ និងហើយទេពកោសល្យខាងបាល់ទាត់ហ្នឹងម៉ង!

កៈ ចាស! ចុះអ៊ំផ្ទះរបស់អ៊ំកាលពីនៅក្មេងមកដល់ឥលូវយ៉ាងមិចដែរហើយ ផ្ទះលក្ខណៈយ៉ាងម៉េចដែរ?

ខៈ អឹម!

កៈ ចុះអ៊ំមានដែរបានទៅមើលទេ? ផ្ទះពីសង្គមពីដើមមក!

ខៈ បានទៅមើលដែរឃើញតែផ្ទះអត់មានអីគិតគូរទេឥលូវ អស់មាននិស្ស័យនិងផ្ទះសំបែងនិងភូមិស្រុកហើយដឹងតែនៅតែលតោលតាមនឹងអញ្ចឹង!

កៈ គេយកអស់ហ៎?

ខៈ ចាស! គេយកអត់ហើយ ឥលូវគេរស់នៅទាំងកូនទាំងចៅគេនិងឃើញយ៉ាងណាក៏គេមិនឲ្យយើងដែរដល់យូរៗទៅខឹង គេតែទោះយើងទារមកវិញក៏គេមិនអោយយើងដែរ បើស្រុកទេសយើងក្រឡាប់ចាក់ ដីអាណាយកអញអំងាប់ហើយនឹកឃើញអញ្ចឹងណាដីស្រុកភូមិម៉ែអញ ស្រុកភូមិក្រឡាប់ចាក់ បានអាណាម៉ែអាណាងាប់ទៅកូនណារស់នៅបានយកដីវិញអំណាស់ប៉ុន្តែរគ្មានទេ!

កៈ អឹម!

ខៈ របស់គេម៉ារហូតមិនមែនរបស់យើងទេ!

កៈ ហ្នឹងហើយកាលដាច់ជំនាន់នឹង!

ខៈ តែនៅស្រម៉ៃឃើញ!

កៈ គេចែករបបឲ្យដែរទេ?

ខៈ គេចែករបបឲ្យតែកាលហ្នឹងអ៊ុំនៅទឹកដីថៃហ៎!

កៈ កាលហ្នឹងអ៊ំនៅថៃហ៎?

ខៈ ចាស!

កៈ កាលហ្នឹងអ៊ំទៅធ្វើអី?

ខ៖   ប្ដីខ្ញុំគេទៅរកស៊ីដល់រកស៊ីយូរៗទៅខ្ញុំទៅតាមគាត់   ខ្ញុំមានកូនតែមួយឥលូវមានកូនបីប្អូន ធ្វើឡូរនំប៉ុងលក់នៅទឹកដីថៃនិងទៅណាបានយូរៗទៅគេជំលៀសឲ្យយើងមកវិញក៏មកភ្នំពេញ និងម៉ង!

ក៖ អឹម!

ខ៖ ចាស!

ក៖ ឆ្នាំណាដែរកាលហ្នឹង?

ខ៖
យូរហើយអូនអើយតាំងពីរកូនខ្ញុំនៅអាយុប្រហែលជាមួយខួបពីរខួបឥលូវកូនអាយុ៣០ទៅ៤០ ជាងហើយ!

ក៖ យូរហើយតាំងពីដាច់អាពតភ្លាមៗ!

ខ៖ ចាស!

ក៖ ចាសអ៊ំនៅប៉ុន្មានឆ្នាំដែរកាលធ្វើនំប៉័ងលក់នៅថៃហ្នឹង?

ខ៖ ប្រហែលជាបីឆ្នាំដែរបានគេឲ្យមកនៅភ្នំពេញវិញបាន!

ក៖ សល់លុយអត់អ៊ំកាលហ្នឹង!

ខ៖ អូនអើយមិនសល់ទេ កាលលក់នំប៉័ងនៅថៃបាននំប៉័ងមួយៗបាត!

ក៖ ហើយអ៊ំចេះភាសារថៃដែរទេ?

ខ៖ ចេះដូចអត់ចេះទេចេះមួយម៉ាត់ៗនិងភ្លេចអស់ទៀតហើយ!

ក៖ ហើយភាសារខ្មែរយើងវិញអ៊ំចេះអានចេះសរសេរល្អទេអ៊ំ?

ខ៖ អត់ចេះតេកូនហើយថាងងឹតអស់!

ក៖ កាលហ្នឹងអ៊ំអត់បានចូលរៀននៅសាលាផង!

ខ៖ ចាសងងឹត!

ក៖ តែអក្ខរកម្មអីគេបង្រៀនអ៊ុំបានចូលរៀនអត់?

ខ៖ គេបង្រៀនដែរប៉ុន្តែរអ៊ំឈឺ កាលហ្នឹងអ៊ំទៅមិនកើតទេ!

ក៖ ចាស!

ខ៖ ឈឺផងកាលហ្នឹងម៉្យាងពោះធំផងណាពិបាកចិត្តប្ដីនៅថៃផងហើយគេទេហៅទៅទៅថៃនិងគេនិងឯងទៅ!

ក៖ អឹម!

ខ៖ ទៅនឹងគេនឹងឯងនឹងទៅ!

ក៖ ចាស! ហើយអញ្ចឹងអ៊ុំនៅវត្តអញ្ចឹងអ៊ុំជាព្រះពុទ្ធសាសនាន់អ៊ុំ?

ខ៖ ចាស!

ក៖ ហើយអ៊ុំកាលសាសនាព្រះពុទ្ធតាំងពីពេលណាដែរអ៊ុំ?

ខ៖ ប្រហែលតាំងពី៤៩អូ៥០អីនឹងចូលវត្ត!

ក៖ អញ្ចឹងហ៎?

ខ៖ ប្រហែល៥០ជាង!

ក៖ ចុះក្រុមគ្រួសារអ៊ំគាត់កាន់សាសនាព្រះពុទ្ធទាំងអស់គ្នាហ៎?

ខ៖ ចាសទាំងអស់គ្នាអូន!

ក៖ ហើយប្រពៃណីអ្វីដែរគ្រួសារអ៊ុំតែងតែប្រារព្ធធ្វើក្នុងសាសនាព្រះពុទ្ធ?

ខ៖ ទំលាប់ខ្មែរយើងហ្នឹង!

ក៖ ទាំងអស់ហ៎អ៊ំ?

ខ៖ ចាសអូន!

ក៖ មានអីក៏ធ្វើតាមនឹងទៅ?

ខ៖ ចាស!

ក៖ ហើយសាសនាព្រះពុទ្ធបានជះឥទ្ធិពលអ្វីខ្លះដែរសំរាប់ជីវិតរបស់អ៊ុំ?

ខ៖
គ្មានអីទេអូនមានតែធម៌អារ្យនិងហើយទុកជាថ្ងៃមុខថ្ងៃក្រោយគោរពព្រះពុទ្ធសាសនាយើងទៅមានអីមានតែប៉ុណ្ណឹងទេ!

ក៖ អញ្ចឹងហ៎?

ខ៖ អឹម!

ក៖ ហើយអ៊ុំអាចប្រាប់ខ្ញុំបានទេថាពីមុនមកដល់ឥលូវអ៊ុំធ្លាប់ជួបបញ្ហាជីវិតអីគេខ្លះ? ដែលធ្វើថាអ៊ុំពិបាកម៉ង?

ខ៖ លំបាកណាស់អូនអើយលំបាកនិងយើងក្រីក្រកាលកូននៅតូចៗដល់កូនធំៗទៅបានរៀងធូមួយកំរិត កាលជំពាក់គេដល់ឥលូវធម្មតាៗ!

ក៖ ចាស! អញ្ចឹងដូចជាពេលអ៊ុំពិបាកចិត្តអ៊ុំតែងធ្វើអីដែរ?

ខ៖ ពិបាកចិត្តណាស់ ពិបាកចិត្តគិតអីមិនចេញណាអូនទោទុក្ខនិងខ្លួនឯងគិតពីនេះទៅនោះពេលយើងក្រគឺលំបាកវេទនាណាស់!

ក៖ អត់ដឹងធ្វើអីម៉ង!

ខ៖ មិនដឹងធ្វើអីទេចេះតែទ្រាំៗអត់សិនទៅ!

ក៖
ហើយបទពិសោធន៍ល្អៗក្នុងជីវិតអ៊ុំតើអ៊ុំធ្លាប់ជួបបទពិសោធន៍អីគេដែរដែលធ្វើឲ្យអ៊ុំសប្បាយចិត្ត?

ខ៖ គ្មានអីដែរសប្បាយចិត្តទេអូនអើយ!

ក៖ ចាស! អញ្ចឹងអ៊ុំមានពាក្យពេចន៍អីដែលចង់ផ្តាំផ្ញើរទៅកូនចៅជំនាន់ក្រោយដែរ?

ខ៖ គ្មានអីទេអូនមានថាឲ្យកូនខំប្រឹងធ្វើការធ្វើងារចិញ្ចឹមជីវិតកូន!

ក៖ ចាស!

ខ៖ ព្រោះសង្គមឥលូវវាមិនស្រួលទេ ខំក៏សាងជីវិតយើងឲ្យបានល្អក្មេងៗឲ្យបានល្អកុំឲ្យវេទនាដូចពេលនេះ

អញ្ចឹងបានខ្ញុំថាខ្ញុំកសាងជាតិមុនវាអាក្រក់ពេកបានជាតិនេះវាលំបាកអញ្ចឹងក៏ខំប្រឹងដើម្បីត្រូវរស់!

ក៖ ចាសអ៊ំ!

ខ៖ ជាតិមុនប្រហែលមានកម្មមានពារហើយអូនដល់ល្មមខំធ្វើបុណ្យលាងកម្មលាងពារឲ្យអស់ជាតិនេះទៅឲ្យជាតិក្រោយឲ្យវាល្អជាងនេះ!

ក៖ ចាស! អញ្ចឹងអ៊ំមានតែប៉ុណ្ណឹងទេអ៊ំ?

ខ៖ ចាសមានតែប៉ុណ្ណឹងទេ!

ក៖ ចាសអគុណអ៊ំច្រើនអញ្ចឹងជូនពរចុងក្រោយសូមឲ្យអ៊ំមានសុខភាពល្អហើយនឹងមានសុភមង្គលក្នុងគ្រួសារ រកស៊ីទទួលទានមានបានណាអ៊ំ!

ខ៖ ចាស!